clearcambodia
A BETTER LIFE

ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០២៦

# ដំណឹងជ្រើសរើសអ្នកស្ម័គ្រចិត្ត

អង្គការស្អាតកម្ពុជា ជាអង្គការគ្រិស្តបរិស័ទក្នុងស្រុកមួយ ដែលបាននិងកំពុងអនុវត្តគម្រោងក្រោមគោល បំណងទឹកស្អាត និង អនាម័យ (WASH)។ បេសកកម្មគឺ ដើម្បីលើកកំពស់គុណភាពទឹក អនាម័យ សុខភាព និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងបណ្តាសហគមន៍គោលដៅដោយប្រើបច្ចេកវិទ្យា និងការអប់រំសមស្រប។
ការងារទាំងអស់ត្រូវបានធ្វើឡើងដោយសហការជាមួយថ្នាក់ដឹកនាំសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ អង្គការស្អាតកម្ពុជាបច្ចុប្បន្ន កំពុងអនុវត្តគម្រោងរបស់ខ្លួននៅក្នុងខេត្តចំនួន ១១ ដូចជា ខេត្តបាត់ដំបង ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង កំពង់ធំ កំពង់ស្ពឺ សៀមរាប ក្រចេះ ស្ទឹងត្រែង ពោធិ៍សាត់ និងរតនគិរី។
អង្គការស្អាតកម្ពុជាត្រូវការជ្រើសរើសអ្នកស្ម័គ្រចិត្តចំនួន០១នាក់ សម្រាប់មុខតំណែងជា **អ្នកស្ម័គ្រចិត្តផ្នែកបច្ចេកទេសដំឡើងចម្រោះទឹក/ Technical Volunteer** ដែលមានទីតាំងនៅ **ភូមិខ្នា សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។**

## ១. ភារកិច្ចទទួលខុសត្រូវក្នុងមុខតំណែង ៖

- ជួយសម្រួលការងាររបស់ប្រធានក្រុមផ្នែកបច្ចេកទេសចម្រោះទឹក និងអ្នកសម្របសម្រួលផ្នែកបច្ចេកទេសចម្រោះទឹកអោយបានត្រឹមត្រូវ តាមបទដ្ឋានដោយមានការចូលរួមពីគ្រួសារដែលទទួលផល។
- ជួយក្នុងការបង្រៀនដល់គ្រួសារដែលទទួលផល និងអ្នកស្ម័គ្រចិត្តភូមិ អំពីការដំឡើងចម្រោះទឹក។
- ជួយសម្រួលការងាររបស់ប្រធានក្រុមផ្នែកបច្ចេកទេសដំឡើងចម្រោះទឹក និងអ្នកសម្របសម្រួលផ្នែកបច្ចេកទេសចម្រោះទឹក និងការបង្រៀនដល់គ្រួសារដែលទទួលផល អោយយល់ពីគុណភាពរបស់ចម្រោះទឹក។
- ជួយសម្រួលការងាររបស់ប្រធានក្រុមផ្នែកបច្ចេកទេសចម្រោះទឹក និងអ្នកសម្របសម្រួលផ្នែកបច្ចេកទេសចម្រោះទឹកនិងពន្យល់ដល់គ្រួសារដែលទទួលផលអំពីដំណើរការនៃការថែរក្សាចម្រោះទឹកអោយបានត្រឹមត្រូវ និងបំផុសស្មារតីម្ចាស់ការ។
- ជួយសម្រួលការងាររបស់ប្រធានក្រុមផ្នែកបច្ចេកទេសចម្រោះទឹក និងអ្នកសម្របសម្រួលផ្នែកបច្ចេកទេសចម្រោះទឹកផ្នែកកិច្ចការរដ្ឋបាល រៀបចំកត់ត្រា ចំនួនចម្រោះទឹកដែលដំឡើងហើយ និងបញ្ចូលទៅក្នុងប្រព័ន្ធ **Iform Builder** ។
- ជួយរៀបចំ និងផ្តល់សម្ភារៈសំខាន់ៗ ដល់អ្នកស្ម័គ្រចិត្តភូមិសម្រាប់ការដំឡើងចម្រោះទឹក។
- ទទួលខុសត្រូវ និងសម្របសម្រួលលើការដំឡើងចម្រោះទឹកថ្មី។

## ២. លក្ខខណ្ឌជ្រើសរើស ៖

- បញ្ចប់ថ្នាក់វិទ្យាល័យ។
- មានបទពិសោធន៍ក្នុងការធ្វើការងារសហគមន៍ ឬសំណង់ផ្សេងៗ។
- ប្រកាន់ខ្ជាប់នូវតម្លៃ និងបេសកកម្មរបស់អង្គការស្អាតកម្ពុជា។
- មានក្រមសិលធម៌ការងារជាអាជីព។
- មានបំណងចង់ធ្វើការងារសហគមន៍។
- មានម៉ូតូផ្ទាល់ខ្លួន និងមានឆន្ទៈក្នុងការជិះម៉ូតូតាមសហគមន៍។

ចំពោះបេក្ខជនទាំងពីរភេទដែលមានចំណាប់អារម្មណ៍ជាមួយមុខតំណែងនេះ
សូមមកទទួលយកពាក្យសុំធ្វើការងារនៅការិយាល័យ **ខេត្តសៀមរាប**ឬអាចទាញយកពាក្យសុំបម្រើការងារជាភាសា ខ្មែរ ឬ អង់គ្លេស ទៅបំពេញហើយបញ្ជូនមកវិញដោយភ្ជាប់ជាមួយប្រវត្តិរូប សង្ខេប (CV & Cover Letter) រួចបញ្ជូនមកកាន់ការិយាល័យ **ខេត្តសៀមរាប** តាមរយៈអាសយដ្ឋានខាងលើ ឬទំនាក់ទំនងទូរស័ព្ទលេខ: (៨៥៥)-២៣៨៨០១៦៤, E-mail: hr@clearcambodia.org, Website: www.clearcambodia.org.

***សំគាល់:*** សូមភ្ជាប់មកជាមួយនូវឯកសារថតចំលងអត្តសញ្ញាណប័ណ្ណ សំបុត្រកំណើត ប័ណ្ណគ្រួសារ ឬសៀវភៅស្នាក់នៅ និង ឯកសារពាក់ព័ន្ធ ផ្សេងទៀត និងរូបថត ៤X៦ ចំនួន ២សន្លឹក។

បន្ទាប់ពីពិនិត្យលើសំណុំបែបបទសុំបំរើការងារអ្នកជាប់បញ្ជីសម្រាំង និងត្រូវបានធ្វើការទំនាក់ទំនង ដើម្បីធ្វើការសម្ភាសន៍។

ថ្ងៃផុតកំណត់ទទួលពាក្យនៅ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៦ ។